ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

# តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌលេខ១៧៣អក
ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៦
សាលក្រមលេខ១២១(ឈ)
ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦

សាលាដំបូងខេត្តកណ្ដាលបានបើកសវនាការជំនុំជម្រះជាសាធារណៈនា ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ដោយមានសមាសភាពដូចតទៅ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៧៣ អ.ក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] ភេទស្រី អាយុ៣៤ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន ភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted]) ម្ដាយឈ្មោះ [redacted](រ) ប្ដីឈ្មោះ [redacted] មានកូន ០៤ នាក់ ទោសពីមុនគ្មាន (ក្នុងឃុំ)។

ជាប់ចោទពីបទៈ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកសំរោង២ ឃុំសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៣៩២ ដកសព ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦។
- បានឃើញ ដីកាដំណោះស្រាយលេខ៥៩៩ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦។
- បានឃើញ សំណុំរឿងជំនុំជំរះលេខ៤២៧ ជរ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦។
- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ៤៣១ ដកចត/១៦ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១៦។

## អង្គហេតុមានដូចតទៅ

កាលថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ វេលាម៉ោង២ៈ៣០ នាទី កម្លាំងកងរាជអាវុធហត្ថខេត្តកណ្ដាល និងក្រុងតាខ្មៅ បានចុះប្រតិបត្តិការបង្ក្រាបជាក់ស្ដែងនៅផ្ទះជនសង្ស័យឈ្មោះ [redacted] ភេទស្រី វ័យ ៣៤ ឆ្នាំ ស្ថិតនៅភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដោយឃាត់ខ្លួនបាន ជនសង្ស័យម្នាក់ឈ្មោះ [redacted]និងដកហូតវត្ថុតាងថ្នាំញៀនចំនួន ០៩ កញ្ចប់តូច ដែលជនសង្ស័យ នេះបានទិញ នៅម្ដុំសង្កាត់ទឹកល្អក់ រាជធានីភ្នំពេញ។

## នាពេលសវនាការ

- ចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៦ វេលាម៉ោង២ៈ៣០ នាទី រសៀល សមត្ថកិច្ចបានឃាត់ខ្លួន និងចូលមកឆែកឆេរនៅផ្ទះរបស់ខ្លួនរកឃើញថ្នាំញៀនចំនួន ០៩ (ប្រាំបួន) កញ្ចប់តូច ទុកនៅក្នុងថតទូដាក់បារី ដើម្បីទុកលក់បន្ត ចំពោះថ្នាំ

Scanned by CamScanner

ញៀនទាំងនេះខ្លួនបានទៅទិញពីឈ្មោ[redacted]ភេទប្រុស អាយុ ៣៦ ឆ្នាំ ក្នុងតម្លៃ ៨០$ (ប៉ែតសិបដុល្លាអាមេរិក) ស្ថិតនៅសង្កាត់ទឹកល្អក់ រាជធានីភ្នំពេញ ខ្លួនមិនបានដឹងថាឈ្មោះ [redacted] ទិញពីអ្នកណាមកទេ ថ្នាំញៀនទាំង ០៩ (ប្រាំបួន) កញ្ចប់តូចនេះខ្លួនបានលក់ឲ្យគេ ០១ (មួយ) កញ្ចប់តូច ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ខ្លួនមានកូនពីរនាក់គ្មានអ្នកចិញ្ចឹមទេ កូនតូចមានអាយុ ៣ ឆ្នាំ កូនបងមានអាយុ ១៤ ឆ្នាំ ហើយខ្លួនដឹងខុសហើយ ខ្លួនទើបតែប្រព្រឹត្តលើកទីមួយទេ ខ្លួនសុំឲ្យតុលាការដោះលែងខ្លួន ដើម្បីទៅរកស៊ីចិញ្ចឹមកូន។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងវត្ថុតាងដែលប្រមូលបាន ឃើញថា ឈ្មោ[redacted] ភេទស្រី អាយុ៣៨ឆ្នាំ ពិតជាបានប្រព្រឹតបទៈរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន។ ដូចនេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់លើជនជាប់ចោទទាំងពីរនាក់ពីបទៈរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងស្នើសុំផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

១ តាមចម្លើយរបស់ជនជាប់ចោទ របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងវត្ថុតាងដែលប្រមូលបាន មានភាពស៊ីសង្វាក់គ្នា ដែលអាចឲ្យតុលាការជឿបានថា ឈ្មោះ [redacted] ពិតជាបានទៅទិញថ្នាំញៀន ដើម្បីទុកលក់បន្តប្រាកដមែន។ គប្បីតុលាការធ្វើការពិចារណាអង្គហេតុ និងលទ្ធផលដែលជនជាប់ចោទបានប្រព្រឹត្ត។

២ ជនជាប់ចោទ បានទៅទិញថ្នាំញៀន ដើម្បីទុកលក់បន្ត ដែលអំពើនេះច្បាប់ចាត់ទុកថាជាបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មិនមែនបទៈ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ទេ គប្បីតុលាការឲ្យឈ្មោះ [redacted] រួចខ្លួនពីបទៈ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន

៣ តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងវត្ថុតាងដែលប្រមូលបាន ឃើញថា ឈ្មោះ [redacted] ភេទស្រី អាយុ៣៨ឆ្នាំ ពិតជាបានប្រព្រឹតបទៈរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន ។ ដូចនេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ពីបទៈ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងស្នើសុំផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

៤ ពេលប្រព្រឹត្តបទល្មើសជនជាប់ចោទ ជានីតិជន មានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើល្មើសច្បាប់ដែលខ្លួនបានប្រព្រឹត្ត ហើយមានចេតនាពិតប្រាកដ ក្នុងការប្រព្រឹត្តអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

Scanned by CamScanner

៥ អំពើរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយរបស់សង្គម។

៦ មានភស្តុតាង និងធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ៣៨ឆ្នាំ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧ វត្ថុតាងមាន ម្សៅក្រាមពណ៌សថ្លា ជាគ្រឿងញៀន ប្រភេទម៉ាទឹកកក ចំនួន ០៩ កញ្ចប់តូច គប្បីរឹបអូសបំផ្លាញចោល។

**ហេតុដូច្នេះសម្រេច**

១ ឲ្យឈ្មោះ [redacted] ភេទស្រី អាយុ ៣៨ ឆ្នាំ រួចខ្លួនពីបទៈរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២ ផ្តន្ទាទោសលើឈ្មោះ [redacted] ភេទស្រី អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០២ ឆ្នាំ ដោយអនុវត្តទោសក្នុងពន្ធនាគារកំណត់រយៈពេល ០៦ ខែ ទោសសល់ពីនេះត្រូវព្យួរទាំងអស់ តាមមាត្រា ១០៤,១០៦,១០៧ និង១០៨ នៃក្រមព្រហ្មទណ្ឌ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣ វត្ថុតាងជា ម្សៅក្រាមពណ៌សថ្លា ជាគ្រឿងញៀន ប្រភេទម៉ាទឹកកកដែលដកហូតបាន ចំនួន ០៩ កញ្ចប់តូច ត្រូវរឹបអូសបំផ្លាញចោល។

៤ សាលាក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ ។

- ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]

Scanned by CamScanner